ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:..................................គ.ម.ក

# លទ្ធផលកិច្ចប្រជុំ

## គណៈកម្មការមូលបត្រកម្ពុជាលើកទី ៣៤

នៅរសៀលថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការមូលបត្រកម្ពុជាលើកទី ៣៤ ដើម្បីពិនិត្យ និងពិភាក្សាលើរបៀបវារៈ ÷

១. ពិនិត្យលើលទ្ធផលនៃការសិក្សារបស់អ្នកជំនាញការនៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) សម្រាប់គម្រោងអភិវឌ្ឍន៍ស្តីពី **"ការជំរុញការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងនៅប្រទេសកម្ពុជា"**។

២. ផ្សេងៗ។

របៀបវារៈទី ១÷ បន្ទាប់ពីការធ្វើបទបង្ហាញរបស់មន្ត្រីជំនាញលើរបាយការណ៍លទ្ធផលនៃការសិក្សារបស់អ្នកជំនាញការធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្នុងក្របខណ្ឌនៃការអនុវត្តជំនួយបច្ចេកទេសសម្រាប់ គ.ម.ក ក្នុងការរៀបចំគម្រោងអភិវឌ្ឍន៍ស្តីពី **"ការជំរុញការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងនៅប្រទេសកម្ពុជា"** អង្គប្រជុំគ.ម.ក បានពិភាក្សាផ្លាស់ប្តូរយោបល់គ្នាយ៉ាងផុលផុសលើបញ្ហាប្រឈម និងអនុសាសន៍ពាក់ព័ន្ធ ដើម្បីជំរុញឱ្យមានការកើនឡើងនូវចំនួនក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង (IPO)។ ជាលទ្ធផលនៃកិច្ចពិភាក្សា ដោយអនុលោមតាមស្ថានភាពជាក់ស្តែងនៃទីផ្សារមូលបត្រកម្ពុជានាពេលបច្ចុប្បន្ន អង្គប្រជុំបានពិនិត្យ និងផ្តល់អនុសាសន៍ ដើម្បីដោះស្រាយបញ្ហាប្រឈម ក្នុងការរៀបចំធ្វើ IPO របស់ក្រុមហ៊ុនមានសក្តានុពលដូចជា ការពិនិត្យ ផ្តល់ការលើកទឹកចិត្តបន្ថែមផ្នែកពន្ធដារក្នុងវិស័យមូលបត្រ, ការបន្តផ្តល់ការបណ្តុះបណ្តាល និងបញ្ជ្រាបការយល់ដឹងបន្ថែមដល់ក្រុមហ៊ុនសក្តានុពលអំពីអត្ថប្រយោជន៍នៃការធ្វើ IPO, ដំណើរការក្នុងការរៀបចំធ្វើ IPO និងឧត្តមានុវត្តន៍នៃអភិបាលកិច្ចសាជីវកម្ម ក៏ដូចជាផ្តល់ការអនុញ្ញាតជាគោលការណ៍ ដល់មន្ត្រីជំនាញ គ.ម.ក ឱ្យបន្តអនុវត្តនូវកម្មវិធីពាក់ព័ន្ធផ្សេងទៀតតាមភាពចាំបាច់ក្នុងការជំរុញឱ្យមានការកើនឡើងនូវចំនួនក្រុមហ៊ុនធ្វើ IPO។

របៀបវារៈទី ២÷ អង្គប្រជុំបានពិនិត្យ និងអនុម័តយល់ព្រមលើកលែងការផ្តល់របាយការណ៍ប្រចាំឆមាស របស់ក្រុមហ៊ុនហ្គ្រេន ធ្វីន អ៊ិនធីណាសិនណល (ខេមបូឌា) ភីអិលស៊ី ព្រមទាំងណែនាំឱ្យមន្ត្រីជំនាញពិនិត្យលើបទប្បញ្ញត្តិ ដែលមានដើម្បីធ្វើការកែសម្រួលដោយលើកលែងការផ្តល់របាយការណ៍ប្រចាំឆមាសនេះ ដល់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈស្រមតាមបរិការ និងឧត្តមានុវត្តន៍ជាអន្តរជាតិ ក្នុងការផ្តល់របាយការណ៍របស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។

អង្គប្រជុំបានបញ្ចប់នៅម៉ោង ១៦ និង ៥០ នាទី ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

គណៈកម្មការមូលបត្រកម្ពុជា

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99 Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh